ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៧៣
ចុះថ្ងៃទី ១០-០១-២០២២

**សាលដីកា**
លេខ: ៣៨ "ក្រVI.ស.អ"
ចុះថ្ងៃទី ២១-០៤-២០២២

# តាមនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ: នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈនៅសាលសវនាការនៃសាលាឧទ្ធរណ៍ភ្នំពេញនាថ្ងៃថ្ងៃចន្ទ ១១រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ ដោយមានសមាសភាពដូចតទៅ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រុមប្រឹក្សា
លោក [redacted] ចៅក្រុមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ: ៧៣ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ ដែលមាន៖

១-ជនជាប់ចោទឈ្មោះ [redacted] SUNDAY ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិនីហ្សេរីយ៉ា មុខរបរប្រធានក្រុមហ៊ុន APPROVE GLOBAL CO.,LTD កន្លែងកំណើតនៅរដ្ឋKOGI ប្រទេសនីហ្សេរីយ៉ា លំនៅមុនពេលឃាត់ខ្លួនបុរី[redacted]វលេខ២១៧ ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] មានកូន៣នាក់ ឪពុកឈ្មោះ[redacted](ស) ម្តាយឈ្មោះ[redacted] (រ) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ (*ប្តឹងឧទ្ធរណ៍*)

*-ឃុំខ្លួននៅ ម១ តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១១៣១ (ង១) ដ.ឃ.ដ ចុះថ្ងៃទី០៥-០២-២០២១ ។*

មានមេធាវី [redacted]ទ្វី[redacted] សង្ខារ[redacted]សុធារិន ការពារសិទ្ធិឱ្យជនជាប់ចោទ ។

មានលោក [redacted] តារា ជាអ្នកបកប្រែភាសាអង់គ្លេសឲ្យជនជាប់ចោទ ។

២-ជនជាប់ចោទឈ្មោះ[redacted] សុភា ភេទស្រី អាយុ៣៣ឆ្នាំ សញ្ជាតិខ្មែរ កន្លែងកំណើតភូមិត្រពាំងស្វាយ ឃុំបល្ល័ង ស្រុកបារាយណ៍ ខេត្តកំពង់ធំ លំនៅបច្ចុប្បន្នបុរីសំបូរមាស ផ្ទះលេខ១៣E ផ្លូវ២១៧ ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្តីឈ្មោះ [redacted] SUNDAY មានកូន៣នាក់ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។

**ជាប់ចោទពីបទ: ឆបោក និងសំអាតប្រាក់** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ រហូតមកដល់ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៣៨ នៃច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និង

ហិរញ្ញប្បទានភេរវកម្ម ។

## **អំពីអង្គហេតុ**

កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ អង្គភាពជំនាញហិរញ្ញវត្ថុនៃនាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែនបានទទួលរបាយការណ៍ប្រតិបត្តិការណ៍សង្ស័យរបស់ឈ្មោះ [redacted] សុភា ភេទស្រី អាយុ៣៣ឆ្នាំ ដែលបានទទួលការផ្ទេរប្រាក់ចូលតាមរយៈធនាគារកម្ពុជាសាធារណៈចំនួនមួយលើក ដែលមានទឹកប្រាក់ចំនួន ២ ៥៨០,៦២ (ពីរពាន់ប្រាំរយប៉ែតសិបដុល្លាក្បៀសហុកសិបពីរ) ដុល្លារអាមេរិក ពីឈ្មោះ [redacted] HOLLINS ដែលមានប្រភពចេញមកពីប្រទេសអូស្ត្រាលី ។ ក្រោយមកនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ ធនាគារកម្ពុជាសាធារណៈបានទទួលសារ SWIFT ពីធនាគារ BANK OF AMERICA របស់សហរដ្ឋអាមេរិកឲ្យបង្វែរប្រាក់ត្រឡប់ទៅវិញ ដោយសារតែប្រតិបត្តិការខាងលើជាប្រតិបត្តិការក្លែងបន្លំ ប៉ុន្តែទឹកប្រាក់ទាំងអស់ត្រូវដកចេញពីគណនីហើយ ។ ក្រោយពីទទួលសារ SWIFT នាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែនបានបើកការស៊ើបអង្កេតបឋម និងឈានទៅដល់ការឃាត់ខ្លួនឈ្មោះ [redacted] SUNDAY ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិនីហ្សេរីយ៉ា និងឈ្មោះ សុខ សុភា ភេទស្រី អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ តាមដីកាបញ្ជាឲ្យចូលខ្លួនលេខ០៤៤ អ.យ.ធ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។ ក្រោយពីបានសាកសួរឈ្មោះ [redacted] SUNDAY បានឆ្លើយថាខ្លួនចូលមកព្រះរាជាណាចក្រកម្ពុជាហើយបានបើកក្រុមហ៊ុនឈ្មោះ APPROVE GLOBAL CO.,LTD និងមានគណនីផ្ទាល់ខ្លួនលេខ ០០០៨០៨ ៦៦០ របស់ធនាគារវឌ្ឍនៈអាស៊ី(ABA) ដោយទទួលប្រាក់ពីក្រៅប្រទេសជាច្រើនដូចជាប្រទេសចិន ប្រទេសកូរ៉េ និងប្រទេសនៅសមាគមអឺរ៉ុប ។ នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ ឈ្មោះ [redacted] SUNDAY បានទទួលប្រាក់ចំនួន ៣០,០០០ (សាមសិបពាន់)ដុល្លារអាមេរិក ពីឈ្មោះ [redacted] MARIES ប៉ុន្តែឈ្មោះ [redacted] MARIES បានប្រាប់ថាឲ្យឈ្មោះ [redacted] SUNDAY យកប្រាក់ទាំងនេះទៅឲ្យឈ្មោះ [redacted] PHILLIP ស្នាក់នៅប្រទេសកម្ពុជា ។ ឈ្មោះ [redacted] SUNDAY ក៏ប្រគល់ប្រាក់ទាំងនេះតាមការណែនាំរបស់ឈ្មោះ [redacted] MARIES នៅចំណុចស្ទឹងមានជ័យថ្មី ចំណែកឈ្មោះ [redacted] សុភា ត្រូវបានឈ្មោះ [redacted] HOLLINS ដែលត្រូវជាបងប្អូនថ្លៃរបស់ឈ្មោះ [redacted] SUNDAY នៅប្រទេសអូស្ត្រាលីផ្ទេរប្រាក់ចំនួន ២ ៥៨០,៦២ (ពីរពាន់ប្រាំរយប៉ែតសិបដុល្លារ)ដុល្លារអាមេរិក ចូលក្នុងគណនីរបស់ឈ្មោះ [redacted] សុភា មែនប៉ុន្តែពុំទាន់បានដកប្រាក់ផង ស្រាប់តែគណនីនេះត្រូវបានដកប្រាក់ចេញវិញ ។ ក្រោយមកឈ្មោះ [redacted] SUNDAY ធ្លាប់បានទទួលបានការផ្ទេរប្រាក់ពីអតិថិជនឈ្មោះ [redacted] KIM ជនជាតិកូរ៉េខាងត្បូងសរុបចំនួន ៤៨០ (បួនរយប៉ែតសិប)ដុល្លារអាមេរិក ផងដែរដោយស្គាល់គ្នាតាមរយៈធនាគារឲ្យទៅជនជាប់ចោទដោយគោលបំណងដើម្បីបំលែងប្រាក់នេះទៅជាផលប្រយោជន៍របស់ខ្លួន ។

***បានឃើញ*** *សាលក្រមព្រហ្មទណ្ឌលេខៈ ៤០៣៤ "ខ១" ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖*

**១-ផ្តន្ទាទោស៖**

១.១-ឈ្មោះ [redacted] SUNDAY ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិនីហ្សេរីយ៉ា ដែលមានអត្តសញ្ញាណខាងលើដាក់ពន្ធនាគារកំណត់ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤០០ ០០០ ០០០(បួនរយលាន)រៀល ។

១.២-ឈ្មោះ [redacted] សុភា ភេទស្រី អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ ដែលមានអត្តសញ្ញាណខាងលើដាក់ពន្ធនាគារកំណត់ ២(ពីរ)ឆ្នាំ តែទោសនេះត្រូវព្យួរទាំងស្រុងតាមបញ្ញត្តិស្តីពីការព្យួរទោសធម្មតានៃក្រមព្រហ្មទណ្ឌ និងពិន័យជាប្រាក់ចំនួន ១០០ ០០០ ០០០(មួយរយលាន)រៀល ។

ពីបទ ឆបោក និងសំអាតប្រាក់ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ រហូត

មកដល់ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៣៨ នៃច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

២-រឹបអូសវត្ថុចាប់យក និងទ្រព្យសម្បត្តិដូចខាងក្រោម៖

-ទូរស័ព្ទដៃម៉ាក Olitech ពណ៌ខ្មៅ ចំនួន០១(មួយ)គ្រឿង (មិនដំណើរការ) ។

-ទូរស័ព្ទដៃម៉ាក SUMSUNG G8 PLUS ពណ៌ខៀវ ចំនួន០១(មួយ)គ្រឿង (មិនដំណើរការ) ។

-ខ្សែកលោហធាតុ ពណ៌លឿងចំនួន០១(មួយ)ខ្សែ ។

-នាឡិកាដៃម៉ា DIESEL ពណ៌ទឹកមាស ចំនួន០១(មួយ)គ្រឿង (មិនដំណើរការ) ។

៣-រឹបអូសប្រាក់សរុបចំនួន ៣០ ៥៩៧,២៦$( សាមសិបពាន់ និងប្រាំរយកៅសិបប្រាំពីដុល្លារអាមេរិក ម្ភៃប្រាំមួយសេន )ដែលរក្សាទុកក្នុងគណនីធនាគារដោយក្នុងនោះ ៖

-ប្រាក់ចំនួន ៣០ ៥៤០,៥៥$(សែសិបប្រាំពីរដុល្លារអាមេរិកសូន្យប្រាំពីរ)បន្សល់ទុកនៅក្នុងគណនីធនាគាររបស់ជនជាប់ចោទឈ្មោះ [redacted] សុភា ដោយក្នុងនោះប្រាក់ចំនួន ០,០៣(សូន្យក្បៀស និងសូន្យបីសេន) បន្សល់ទុកនៅក្នុងគណនីធនាគារលេខ ០០០៥១៤៣១០ ចេញដោយធនាគារវឌ្ឍនៈអាស៊ីចំកាត់ ប្រាក់ចំនួន ១៦,៣៧ (ដប់ប្រាំមួយដុល្លារអាមេរិក និងសាមសិបប្រាំពីរសេន) បន្សល់ទុកនៅក្នុងគណនីធនាគារលេខៈ ២០១០០១១០០០០២១៨៣១ ចេញដោយធនាគារ អ អេច ប៊ី ប្រាក់ចំនួន១០,០០$(ដប់ដុល្លារអាមេរិក) បន្សល់ទុកនៅក្នុងគណនីធនាគារលេខ ៤៣៩០០២៩ ចេញដោយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ប្រាក់ចំនួន ១១,៦៧$ (ដប់មួយដុល្លារអាមេរិក និងហុកសិបប្រាំពីរសេន) បន្សល់ទុកនៅក្នុងគណនីធនាគារលេខ ២៦០០២៣០០១៦២៦៨ ចេញដោយធនាគារកម្ពុជាសាធារណៈ និងប្រាក់ចំនួន១០$ (ដប់ដុល្លារអាមេរិក) បន្សល់ទុកក្នុងគណនីធនាគារដែលមានលេខ ០៨០០០០៩៥៣៨៥០ ចេញដោយធនាគារសាខមប៉ៃង ។

-និងប្រាក់ចំនួន៨.៦៤$ (ប្រាំបីដុល្លារអាមេរិក និងហុកសិបបួនសេន) ទៀតបន្សល់ទុកនៅក្នុងគណនីធនាគាររបស់ក្រុមហ៊ុនឈ្មោះ APPROVE GLOBAL CO.,LTD ដែលមានគណនីលេខ ០០១២៥២៤០៤ ចេញដោយធនាគារវឌ្ឍនៈអាស៊ីចំកាត់ ។

៤-ប្រគល់វត្ថុចាប់យក៖

-លិខិតឆ្លងដែនលេខ A៥០២១០៤៤១ ចំនួន០១ (មួយ)ក្បាល ។

-សៀវភៅការងារជនបរទេសចំនួន០១ (មួយ)ក្បាល ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] SUNDAY និងជនជាប់ចោទឈ្មោះ [redacted] សុភា និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**បានឃើញ** សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខៈ ១១៣២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ របស់ឈ្មោះ [redacted] SUNDAY សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ៤០៣៤ "ខ១" ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច *ទាំងមូលនៃសេចក្តីសម្រេច* ។

**បានឃើញ** របាយការណ៍សំណុំរឿងព្រហ្មទណ្ឌ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២ របស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ។

**បានឃើញ** សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ។

**បានឃើញ** ពាក្យសុំលើកពេលជំនុំជម្រះរឿងក្តី ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] សុភា ។



Scanned with CamScanner

**បានឃើញ** ពាក្យសុំលើកពេលជំនុំជម្រះរឿងក្តី ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ របស់មេធាវី ចិត្ត សង្ហារ, ឈុន សុធារិន ការពារសិទ្ធិឲ្យជនជាប់ចោទ ។

## នាពេលសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះប្រាប់សិទ្ធិដល់ជនជាប់ចោទ និងអានរបាយការណ៍អំពីរឿងក្តី ។

-ជនជាប់ចោទឈ្មោះ [redacted] SUNDAY បានធ្វើសេចក្តីសន្និដ្ឋានថាៈ ប្រាក់ដែលផ្ញើរចូលគណនីយខ្លួនមានមកពីកូរ៉េខាងត្បូង អ៊ីស្រាអែល ចិន អូស្រ្តាលី និងប្រេស៊ីល ។ ប្រាក់ទាំងនេះគឺប្រាក់ដែលខ្លួនទទួលបានពីការលក់ទំនិញខ្ទឹមស និងជាកម្រៃដែលទទួលបានពីសេវាកម្មប្រឹក្សាយោបល់ដល់ភ្ញៀវរបស់ខ្លួន ។ ប្រតិបត្តិការផ្ទេរប្រាក់គឺមានចំនួនច្រើនលើកមិនបានចាំចំនួនទេព្រោះផ្ទេរមកម្តងបន្តិចៗច្រើនសារ ។ ចំពោះឈ្មោះ [redacted] HOLLINS ជាបងថ្លៃស្រីរបស់ខ្លួនគាត់រស់នៅប្រទេសអូស្រ្តាលី ខ្លួនបានដឹងថាមានការផ្ទេរប្រាក់ពីឈ្មោះ [redacted] HOLLINS ចូលមកគណនីយខ្លួន ។ ប្រាក់ទាំងនេះគឺជាប្រាក់ដែលគាត់ជួយខ្លួននៅពេលជួបការខ្វះខាតជីវភាព ដោយផ្ញើរជាប្រាក់អូស្រ្តាលីប៉ុន្តែធនាគារប្តូរមកជាប្រាក់ដុល្លាអាមេរិក មានចំនួន ២ ៥៨០ដុល្លារ ។ ខ្លួនមិនបានសំអាតប្រាក់ទេ ខ្លួនបើកក្រុមហ៊ុន ហើយភ្ញៀវទិញខ្ទឹមសផ្ញើរប្រាក់ចូលគណនីយខ្លួន និងជាប្រាក់ថ្លៃសេវាកម្មប្រឹក្សាយោបល់ ។ ចំពោះប្រាក់ចំនួន ២ ៥៨០ដុល្លារ គឺខ្លួនឲ្យឈ្មោះ [redacted] HOLLINS ផ្ញើរមកគណនីយរបស់ប្រពន្ធខ្លួន ប៉ុន្តែផ្ញើមកខុសលេខគណនីយ ទើបប្រាប់ឲ្យគាត់ដកវិញ និងផ្ញើរមកម្តងទៀត ។

-តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថាៈ តាមការអះអាងរបស់ជនជាប់ចោទថាប្រាក់នេះគឺមានប្រភពប៉ុន្តែតាមការពិនិត្យឃើញថាមិនមានប្រភពច្បាស់លាស់ទេ ។ ចំពោះឈ្មោះ [redacted] HOLLINS ជនជាប់ចោទអះអាងថាជាសាច់ញាតិខ្លួនប៉ុន្តែមិនមានឯកសារអ្វីបញ្ជាក់ទេ ហើយគាត់ថាបានឲ្យគាត់ដកប្រាក់វិញ ប៉ុន្តែជាក់ស្តែងប្រពន្ធគាត់បានដកប្រាក់នោះរួចហើយ ។ គណនីយរបស់ជនជាប់ចោទគឺមានភាពមិនមានប្រក្រតីទេ តាមការស៊ើបអង្កេតបឋមរបស់នាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែនបានឃើញថាមានការសម្អាតប្រាក់ពិតមែន ។ សាលក្រមព្រហ្មទណ្ឌលេខៈ ៤០៣៤ "ខ១" ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ គឺមានសំអាងហេតុ និងសំអាងច្បាប់ត្រឹមត្រូវហើយ គប្បីតម្កល់ទុកបានការដដែល ។

-មេធាវី [redacted] វុទ្ធី ការពារសិទ្ធិឲ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថាៈ ចំពោះប្រាក់ចំនួន ២ ៥៨០ ដុល្លារ គឺជាប្រាក់ដែលបងស្រីរបស់កូនក្តីខ្លួនបានផ្ញើរឲ្យ ប៉ុន្តែខុសលេខគណនីយកូនក្តីខ្លួនបានប្រាប់ឲ្យគាត់ដកវិញហើយផ្ញើរមកម្តងទៀត តែប្រពន្ធគាត់បានដកបាត់ហើយ ទើបធនាគារនៅសហរដ្ឋអាមេរិចបញ្ជូនព័ត៌មានមកធនាគារនៅកម្ពុជាឲ្យបង្វិលប្រាក់ទៅវិញ ។ រឿងនេះមិនមែនជាការសម្អាត់ប្រាក់ទេគឺជាការផ្ញើខុសលេខគណនីយប៉ុណ្ណោះ ។ ចំពោះប្រាក់ដែលកូនក្តីខ្លួនទទួលគឺគាត់បើកក្រុមហ៊ុនផ្តល់សេវាកម្មផ្នែកពិគ្រោះយោបល់ ការគ្រប់គ្រង មានភ្ញៀវជនជាតិផ្សេងៗគ្នាដូចជា ចិន អូស្រ្តាលី ជាដើម និងចំណូលដែលគាត់ទទួលបានពីការប្រកបអាជីវកម្ម មិនមានមូលដ្ឋានណាមួយដែលបញ្ជាក់ថាប្រាក់នោះគឺជាផលនៃបទល្មើសទេ ។ សំណូមពរសូមបដិសេធសាលក្រមព្រហ្មទណ្ឌលេខៈ ៤០៣៤ "ខ១" ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ចោលជាអសារបង់ និងសម្រេចកូនក្តីខ្លួនរួចផុតពីការចោទប្រកាន់ ។

-ជនជាប់ចោទឈ្មោះ [redacted] SUNDAY បានធ្វើសេចក្តីសន្និដ្ឋានថាៈ សំណូមពរសូមលើកលែងការចោទប្រកាន់ និងដោះលែងខ្លួនឲ្យមានសេរីភាពដើម្បីបានទៅជួបជុំគ្រួសារវិញ ។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់ជនជាប់ចោទ និងមេធាវីការពារសិទ្ធិ

-ក្រោយពីបានពិនិត្យកស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

# សាលាឧទ្ធរណ៍ភ្នំពេញយល់ឃើញថា

១-តាមសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ: ១១៣២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ របស់ឈ្មោះ [redacted] SUNDAY សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: ៤០៣៤ "ខ១" ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច គឺធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ អាចទទួលសំណុំរឿងព្រហ្មទណ្ឌខាងលើនេះមកជំនុំជម្រះបានយោងតាមមាត្រា៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា៣៨២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-តាមពាក្យសុំលើកពេលជំនុំជម្រះរឿងក្តី ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] សុភា បានស្នើសុំពន្យាពេលសនវនាការ ប៉ុន្តែតាមការពិនិត្យសំណុំរឿងឃើញថាជនជាប់ចោទឈ្មោះ [redacted] សុភា ពុំបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿងនេះឡើយ ។ ហេតុនេះជនជាប់ចោទឈ្មោះ [redacted] សុភា ពុំមានសិទ្ធិក្នុងការស្នើសុំពន្យាពេលសវនាការក្នុងសំណុំរឿងក្តីនេះទេ ។ ដោយឡែកតាមពាក្យសុំលើកពេលជំនុំជម្រះរឿងក្តី ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ របស់មេធាវី [redacted] សង្វារ, [redacted] សុជាវិន ការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] SUNDAY បានស្នើសុំពន្យាពេលសវនាការ ដោយមូលហេតុពួកខ្លួនបានលិខិតអញ្ជើញឲ្យចូលទៅកាន់មន្ទីរស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ។ ក្រុមប្រឹក្សាជំនុំជម្រះ **យល់ឃើញថា** ពុំមានភាពចាំបាច់ដែលត្រូវពន្យាពេលសវនាការឡើយ ដោយហេតុថាជនជាប់ចោទមានវត្តមានក្នុងពេលសវនាការហើយ និងមានមេធាវីការពារសិទ្ធិត្រឹមត្រូវតាមច្បាប់ហើយ ។ ហេតុនេះការស្នើសុំខាងលើគឺជាការអូសបន្លាយពេលវេលាដែលនាំឲ្យកកស្ទះសំណុំរឿងប៉ុណ្ណោះ ហេតុនេះសាលាឧទ្ធរណ៍ភ្នំពេញ គប្បីបន្តនីតិវិធីតាមកាលបរិច្ឆេទ ។ (for delay)

៣-តាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការបានលើកឡើងថា: តាមការអះអាងរបស់ជនជាប់ចោទថាប្រាក់នេះមានប្រភពច្បាស់លាស់ ប៉ុន្តែតាមការពិនិត្យឃើញថាមិនមានប្រភពច្បាស់លាស់ទេ ។ ចំពោះឈ្មោះ [redacted] HOLLINS ជនជាប់ចោទអះអាងថាជាសាច់ញាតិខ្លួន ប៉ុន្តែមិនមានឯកសារអ្វីបញ្ជាក់ទេ ហើយគាត់ថាបានឲ្យគាត់ដកប្រាក់វិញ ប៉ុន្តែជាក់ស្តែងប្រពន្ធគាត់បានដកប្រាក់នោះរួចហើយ ។ គណនីយរបស់ជនជាប់ចោទគឺមានភាពមិនមានប្រក្រតីទេ តាមការស៊ើបអង្កេតបឋមរបស់នាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែនបានឃើញថាមានការសម្អាតប្រាក់ពិតមែន ។ សាលក្រមព្រហ្មទណ្ឌលេខ: ៤០៣៤ "ខ១" ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ គឺមានសំអាងហេតុ និងសំអាងច្បាប់ត្រឹមត្រូវហើយ គប្បីតម្កល់ទុកបានការដដែល ។ ក្រុមប្រឹក្សាជំនុំជម្រះគប្បីពិចារណា និងសម្រេច ។

៤-តាមសេចក្តីសន្និដ្ឋានរបស់ជនជាប់ចោទ និងមេធាវីការពារសិទ្ធិបានលើកឡើងថា: ចំពោះប្រាក់ចំនួន ២ ៥៨០ ដុល្លារ គឺជាប្រាក់ដែលបងស្រីរបស់កូនក្តីខ្លួនបានផ្ញើរឲ្យ ប៉ុន្តែខុសលេខគណនីយ កូនក្តីខ្លួនបានប្រាប់ឲ្យគាត់ដកវិញហើយផ្ញើរមកម្តងទៀត តែប្រពន្ធគាត់បានដកបាត់ហើយ ទើបធនាគារនៅសហរដ្ឋអាមេរិកបញ្ជូនព័ត៌មានមកធានាគារនៅកម្ពុជាឲ្យបង្វិលប្រាក់ទៅវិញ ។ រឿងនេះមិនមែនជាការសម្អាត់ប្រាក់ទេគឺជាការផ្ញើខុសលេខគណនីយប៉ុណ្ណោះ ។ ចំពោះប្រាក់ដែលកូនក្តីខ្លួនទទួលបានគឺគាត់បើកក្រុមហ៊ុនផ្តល់សេវាកម្មផ្នែកពិគ្រោះយោបល់ ការគ្រប់គ្រង មានភ្ញៀវជនជាតិផ្សេងៗគ្នាដូចជា ចិន អូស្ត្រាលី ជាដើម និងចំណូលដែលគាត់ទទួលបានពីការប្រកបអាជីវកម្ម ។ មិនមានមូលដ្ឋានណាមួយដែលបញ្ជាក់ថាប្រាក់នោះគឺជាផលនៃបទល្មើសទេ ។ សំណូមពរសូមបដិសេធសាលក្រមព្រហ្មទណ្ឌលេខ: ៤០៣៤ "ខ១" ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ចោលជាអសារបង់ និងឲ្យកូនក្តីខ្លួនរួចផុតពីការចោទប្រកាន់ ។ ក្រុមប្រឹក្សាជំនុំជម្រះគប្បីពិចារណា និងសម្រេចតាមច្បាប់ ។

៥-តាមសំអាងហេតុបន្តបន្ទាប់ខាងលើ និងកស្តុតាងទាំងអស់ក្នុងសំណុំរឿងក្រុមប្រឹក្សាយល់ឃើញ

ថា: តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] SUNDAY បានឆ្លើយទទួលស្គាល់អង្គហេតុថា: មានការផ្ញើរប្រាក់មកពីកូរ៉េខាងត្បូង អ៊ីស្រាអែល ចិន អូស្ត្រាលី និងប្រេស៊ីល ជាប្រាក់ដែលទទួលបានពីការលក់ខ្ទឹមស និងកម្រៃដែលខ្លួនផ្តល់សេវាកម្មប្រឹក្សាយោបល់ដល់ភ្ញៀវ ។ ប្រតិបត្តិការផ្ទេរប្រាក់ គឺមានចំនួនច្រើនលើកមិនបានចាំចំនួនប្រាក់ទេព្រោះផ្ទេរមកម្តងបន្តិចៗ ។ ឃើញថាជនជាប់ចោទពុំមានឯកសារភស្តុតាងអ្វីដែលបញ្ជាក់ពីប្រភពដែលខ្លួនទទួលប្រាក់ឲ្យបានច្បាស់លាស់ទេគឺមានតែការដោះសារដោយផ្ទាល់មាត់ប៉ុណ្ណោះ ក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា មានភស្តុតាង និងធាតុផ្សំដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] SUNDAY ដូចការចោទប្រកាន់ខាងលើមែន ។

៦-មានពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] SUNDAY ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិនីហ្សេរីយ៉ា(អត្តសញ្ញាណដូចខាងលើ) ពីបទ: **ឆបោក និងសំអាតប្រាក់** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ រហូតមកដល់ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៣៨ នៃច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

៧-សំអាងហេតុដូចក្នុងសាលក្រមព្រហ្មទណ្ឌលេខ: ៤០៣៤ "ខ១" ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ គឺមានលក្ខណៈសមស្របតាមអង្គហេតុ និងអង្គច្បាប់ហើយសាលាឧទ្ធរណ៍ភ្នំពេញឯកភាពនឹងសំអាងហេតុនេះមិនចាំបាច់លើកមកសរសេរបញ្ជាក់ជាថ្មីឡើយ ។

៨-សាលក្រមព្រហ្មទណ្ឌលេខ: ៤០៣៤ "ខ១" ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ សម្រេចតម្កល់សាលក្រមខាងលើនេះទុកជាបានការដដែល ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១-ទទួលសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ: ១១៣២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] SUNDAY គឺធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ: ៤០៣៤ "ខ១" ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកបានការដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] SUNDAY តាមច្បាប់ ។

៤-សាលដីកានេះបានជំនុំជម្រះនាថ្ងៃចន្ទ ១១រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងប្រកាសជាសាធារណៈនាថ្ងៃព្រហស្បតិ៍ ៥រោច ខែចេត្រ ឆ្នាំខាលចត្វាស័កព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២។

ទុកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ៥រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២

បានឃើញ
ប្រធានក្រុមប្រឹក្សា

[redacted]

№៦

ក្រឡាបញ្ជី

[redacted]

Scanned with CamScanner